# ក្រុងសុភមិត្រ

ឧកញ៉ាកោសាធិបតី **ភៅ** ចាងហ្វាងឃ្លាំងមណីរ័តន៍

តែងជាពាក្យកាព្យ

គណៈរដ្ឋមន្ត្រី និង សម្ដេចសង្ឃនាយកទាំងពីរគណៈបានអនុញ្ញាតហើយ

បោះពុម្ពឡើងវិញ ចំនួន ២០០០ ច្បាប់
តាមច្បាប់បោះពុម្ពលើកទី ៨ ឆ្នាំ ១៩៧២

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

គ.ស ១៩៩៨

# សេចក្តីប្រារព្ធ
# ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅ « ក្រុងសុភមិត្រ » ត្រូវបានបោះពុម្ពឡើងវិញ ដោយបាន ទទួលការឧបត្ថម្ភពីអង្គការជំនួយសង្គ្រោះស៊ូជប៉ុន (JSRC) និងពីគណៈកម្មាធិការជប៉ុន នៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព ( WCRP ) ។

ការបោះពុម្ពសៀវភៅនេះឡើងវិញ ធ្វើឡើងដោយថតចម្លងពីសៀវភៅ ច្បាប់ដើមទាំងស្រុង ។ ហេតុនេះ ប្រសិនបើមានកំហុសអក្ខរាវិរុទ្ធក្តី កំហុសក្នុងការ រៀបរៀងឃ្លាក្តី នោះគឺជាលក្ខណៈដែលមានក្នុងច្បាប់ដើមពីមុនមក ។

ពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសជាមុន ចំពោះកង្វះខាតផ្សេងៗ ដែលអាចនឹងកើតមានដោយអចេតនា ក្នុងការបោះពុម្ពជាថ្មីឡើងវិញនេះ ។

ពុទ្ធសាសនបណ្ឌិត្យ នឹងខិតខំចាត់ការបោះពុម្ពសៀវភៅសិក្សា និង សៀវភៅអានគ្រប់បែបយ៉ាងផ្សេងទៀត ដើម្បីកូនចៅខ្មែរជំនាន់ក្រោយបានសិក្សា រៀនសូត្រផង ដើម្បីរក្សាមរតកវប្បធម៌ អក្សរសាស្ត្រ អោយបានគង់វង្ស និងរីក ចំរើនផង ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអង្គការជំនួយសង្គ្រោះស៊ូ ជប៉ុន(JSRC) និងក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ដែលបានផ្តល់ការឧបត្ថម្ភដ៏ឧត្តុង្គឧត្តមដល់ការបោះពុម្ពសៀវភៅនេះ ។

ភ្នំពេញ, ខែកញ្ញា ឆ្នាំ ១៩៩៨

ពុទ្ធសាសនបណ្ឌិត្យ

# ដំណើរក្នុងការបោះពុម្ពគ្រាទី ៤

រឿងក្រុងសុភមិត្រនេះ ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយ៣គ្រា រួចមកហើយ ដោយចែករំលែកជាបីខ្សែ ។ ការរំលែកនេះ គោរពទៅតាមសាស្ត្រាស្លឹករឹត ជាច្បាប់ដើម ដែលចែកជាបីកណ្ឌដូច្នេះដែរ ។

ប៉ុន្តែនៅពេលបោះពុម្ពគ្រាទី ៤ នេះតទៅ គណៈកម្មការខាងបោះពុម្ពយល់ឃើញថា: គួរតែប្រមូលគ្នាជាមួយក្បាលឡើង ដើម្បីឲ្យងាយស្រួលដល់អ្នកអានទូទៅ ដែលនិយមអានរឿងនេះផង និងស្រួលដល់អ្នកសិក្សាសម័យថ្មី ដែលត្រូវការយករឿងនេះទៅសិក្សាតាមកម្មវិធីនៅមធ្យមសិក្សាផង ។ រីឯបទានុក្រម សម្រាប់ពន្យល់ពាក្យពិបាកៗ ខ្លះក្នុងរឿងនេះ ដែលពីមុនមកមានបោះនៅផ្នែកខាងចុងសៀវភៅរៀងរាល់ភាគនោះ, ឥឡូវក៏ត្រូវប្រមូលបញ្ចូលគ្នាតាមលំដាប់អក្សរ រៀបដាក់តែមួយកន្លែងខាងចុងបំផុតដែរ ។

ចំពោះសំនួនវោហារ ឃ្លាល្បះ ក្នុងផ្នែករឿងទាំងអស់ យើងទុកនៅដូចដើម ឥតមានកែប្រែឡើយ កែខ្លះតែអក្ខរាវិរុទ្ធនិងពាក្យតក់បន្តិចបន្តួចៗ

ខែធ្នូ គ.ស. ១៩៦៤

**ពុទ្ធសាសនបណ្ឌិត្យ**

# អារម្ភកថា

រឿងគ្រុឌសុភមិត្រនេះ គឺរឿង សុភមិត្រជាតកទី ៩ ក្នុងរឿង ៥០ ជាតក៍ ( បញ្ញាសជាតក ) ។ នេះជារឿងព្រេង ដែលមានគេដំណាលមកពីបុរាណ ព្រះសង្ឃលាវនៅស្រុកជៀងម៉ៃ ១ អង្គ បានតែងជាភាសាមគធៈ រួមទាំងអស់ ៥០ រឿង ក្នុងពុទ្ធសករាជ ២.០០០ ដល់ ២.២០០ ហៅថា គម្ពីរបញ្ញាសជាតក មាននៅតែក្នុងប្រទេសខ្មែរ លាវ និងសៀមប៉ុណ្ណោះ ក្រៅពីនេះគ្មាន ។ ខ្មែរយើងក៏បានប្រែតែងជាពាក្យកាព្យជាច្រើនរឿង តាមដែលទឹកឃើញ គឺរឿងព្រះសុធន សុធនូ សព្វសិទ្ធិ សុភមិត្រ វនាវ័ន យសកិត្តិ សុវណ្ណស័ង្ខ វរវង្សសូរវង្ស បុញ្ញសារសិរសារ ជាដើម ។ រឿងសុភមិត្រនេះ ឧកញ៉ាកោសាធិបតី "កៅ" ចាងហ្វាងក្រុមព្រះឃ្លាំងមណីរ័ត្ន៍ បានតែងឡើងជាពាក្យកាព្យ ភាសាខ្មែរ ៣ ខ្សែ ទុកឲ្យមហាជនមើល រាប់រួមក្នុងពួករឿងវណ្ណគតិរបស់ខ្មែរ ១ រឿង ។

វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ឃើញថារឿងនេះ ជាវណ្ណគតិអក្សរសាស្ត្រ ១ រឿងដែរ ទើបចាត់ឲ្យចម្លងចេញពីសាស្ត្រាស្លឹករឹតដែលមានតម្កល់ក្នុងវិជ្ជាស្ថាននេះ យកមកពិនិត្យផ្ទៀងផ្ទាត់ ហើយចាត់ការបោះពុម្ពផ្សាយឡើងដើម្បីរក្សាស្នាដៃកវីនិពន្ធខ្មែរសម័យបុរាណ ទុកជាកេរ្តិ៍ដំណែលតទៅ ។

# គតិរបស់រឿង

រឿងនេះ ជាគតិដែលគួរកាន់យកនិងគួរលះបោល គឺព្រះអសុកមិត្រជាអនុជក្រុងសុកមិត្រ ។ ក្រុងសុកមិត្រទ្រង់ព្រះមេត្តាប្រោសប្រទានយសសក្តិជាទីឧបរាជ តែមិនស្កប់ចិត្តនឹងសម្បត្តិប៉ុណ្ណោះ បានក្បត់លបលួចលើកទ័ពមកដណ្តើមរាជសម្បត្តិក្រុងសុកមិត្រជាព្រះជេដ្ឋាធិរាជ ។

ក្រុងសុកមិត្រមិនបានច្បាំងតទល់ទៅវិញ ដោយព្រះអង្គជាពោធិសត្វ មានព្រះទ័យស្លូតសុភាព ទ្រង់ឈ្វេងយល់ទោសក្នុងការកាប់សម្លាប់ ទើបស្តេចកៀសយកតែព្រះអង្គនឹងមហេសី ព្រះរាជបុត្រពីអង្គចេញចាកព្រះនគរទៅ ដោយឥតមានអាឡោះអាល័យដល់រាជសម្បត្តិនោះឡើយ តែនៅមានកុសលទ្រទ្រង់ វេលាក្រោយទ្រង់បានសោយរាជ្យឯនគរតក្កសិលាទៀត ។

រឿងនេះ សឲ្យឃើញសមដូចព្រះពុទ្ធភាសិតថា " **សព្វញ្ចេ បឋវី ទជ្ជា នេវ នំ អភិរាធយេ** " ធម្មតាបុគ្គលពាល ទោះអ្នកណាមួយលើកសម្បត្តិឲ្យទាំងផែនដី ក៏មិនអាចធ្វើឲ្យត្រេកអរបាន ។

និយាយពីវោហារកាព្យវិញ រឿងនេះក៏រាប់ថាជាកាព្យល្អមួយដែរ

ដោយឧកញ៉ាគោសាធិបតី "គោ" នេះ ល្បីឈ្មោះ គួរបញ្ចូលក្នុងពួកចិត្តករមួយដែរ ។

អ្នកមើលរឿងនេះ គួរពិចារណាឲ្យឃើញ :

១- ទោសនៃបុគ្គលជាអ្នកអកតញ្ញូ ដូចជាព្រះអស្សុកមិត្រប្រទូសរាយអ្នកមានគុណូបការៈលើខ្លួន ចាត់ជាបាបធ្ងន់បំផុត ។

២- គួរពិនិត្យវោហាររបស់រឿងនេះ និងគួរទុកជាក់ជារឿងពិរោះល្អឬទេ ? ទើបមិនខូចប្រយោជន៍ក្នុងការដែលមើលរឿង ។



បទភាគគតិ

នមាមិហំ ពុទ្ធសេដ្ឋំ លោកុត្តមោ
គុណាគុណំ សរំធម្មោ ទិយឋយោ
មារសេនំ ។
គុនមាមិ សមោបិសិ ឥធធម្មំ
លោកសេដ្ឋោ ធម្មោសរំ ភតាញាណំ
សេដ្ឋធម្មោ ។
នមាមិហំ សុសាធកំ អនាសវោ
សរំមកំ សរំធម្មោ គុណាករោ
ភចាលិនំ ។
អញខំអភី ភាទររឡើយ ក្រញក្រាបសិរសំ
សរសើរពុទ្ធគុណ អនន្តសេដ្ឋ ស្ងួតសោឡសំ
ប្រៀបផ្ទឹមពុំបាន ។
៤ – សត្តាអគ្គោ ឯកឥតទុតិយោ វរពោធិញាណ
ជាតិជាគ្រូគ្រប់ ត្រៃភពភូមិឋាន លុះឱភាទទាន
មូលមកភក្តី ។
តិណ្ណោសត្តំ សុសាគរំ សុខសមសិរី
ចៀសចាកវេទនា ជរាព្យាធិ ជួបជុំជាតី
សម្រេចវេរា ។
បង្គំព្រះធម៌ បីដូចសុព័ណ៌ សុវណ្ណកេត្រា
នានាំសត្វផង ឆ្លាស់ឆ្លងជលសា គរគៀរកាន់មហា
នគរនិព្វាន ។

បង្គំព្រះសង្ឃ ប្រសើរភិម- ង្គលគុណប្រធាន
ថ្លែងធម៌ទេសនា ឧបមាដូចយាន ចម្លងសត្វបាន
លុះលោកុត្តរ ។

នយេអតីតំ ពុទ្ធឱស្ឋ ធម្មទេសនា
ជាតិពុទ្ធំ គាថាវណ្ណនា គម្ពីរបញ្ញា
ជ្រាបជ្រះញេយ្យញាណ ។

១០ យើងដឹងដោយសារ ព្រះអង្គទេសនា ប្រោសជនសព្វឋាន
ទើបខ្ញុំចែងចង ទំនងនិទាន សូមទេពសព្វឋាន
ជ្រោមជួយជយា ។

អញខ្ញុំសូមពរ ទេពទសនិករ ជ្រោមជ្រែងរក្សា
សួគ៌សោឡសព្រហ្ម សូមសុំជយា សូមតេជចេស្តា
ភិរម្យឫទ្ធី ។

សូមតេជសូមបុណ្យ សូមជ័យសូមជន្ម មោះមកទៀងទី-
ឃាយុយឺនយូរ បរិបូណ៌បារមី សុខសម្រឹទ្ធី
បានដូចប្រាថ្នា ។

ខ្ញុំសូមពរពី ព្រះឥន្ទ្រធិបតី ឋិតឋានសួគ៌ា
សូមជួយក្រវែន ចំរើនចេស្តា ចៀសចាករោគា
ជរាព្យាធី ។

សកវាជជួបជួន ឯកស័ប្តទោស្វន ស្វស្តីស័ក្តិបារមី
មាសមាឃពារពុធ ប្រាកដប្រាំបី រោចរ៏សម្តី
សម្តែងកាព្យា ។



១៩- អញខ្ញុំឈ្មោះ ភៅ បម្រើគាល់ហ្វៅ ជាខ្ញុំក្សត្រា
ព្រះរាជទាន ប្រោសប្រាណករុណា ឲ្យជាឧកញ៉ា
កោសាធិបតី ។

ជាចៅហ្វាយឃ្លាំង មណីរ័ត្នតែងតាំង កាព្យកិច្ចនាំនី
ទានទងដំណើរ សរសើរពោធិ- សត្វសាងបារមី
ក្នុងហាសិបជាតិ ។

សកវាជព្រះសង្ឃ ពជាឯកតាំង ប្រែពីនិបាត
បញ្ញាសជាតក ទៀងទុកជាអាទិ៍ ទើបខំសង្វាត
សង្វេគគិតគន់ ។

ចងជាកិច្ចកាព្យ ពាក្យពេចន៍សុភាព ទុកទៅជាបុណ្យ
តំណជាក្រោយ ទុកឲ្យអស់ជន សូត្ររៀនគួរគន់
គួរគិតអនិច្ចា ។

ក្បិតពោធិសត្វ លំបាកប្រាសព្រាត់ ព្រះរាជបុត្រា
ប្រាសព្រះមហេសី ទូរទីឃ្លាតឃ្លា ដោយកម្មបុរា
បុរាណជាតិ ។

២០- ក្រែងខ្ញុំលើសលស់ ដំណើរខាតខុស ពាក្យពេចន៍ពុំពី-
រោះរៀយរ៉ះរាប កិច្ចកាព្យនាំនី- ទានទងសម្តី
លើសលស់បាត់បង់ ។

២១- បើអ្នកឯណា មួយមានប្រាជ្ញា សូមជួយតម្រង់
ដោយកលកាព្យកិច្ច ពាក្យពេចន៍ផ្ចិតផ្ចង់ ផ្ចប់ផ្ចល់ឲ្យគង់
ទុកតសាសនា ។

## បទព្រហ្មគីតិ

១ – កិរកាលកប្បខណ្ឌខាំង ជាកំចាំងលង់ហើយណា
មែនមានមហាក្សត្រា សោយសម្បត្តិសម្បូណ៌គ្រង ។
នាមព្រះបាទសុភមិត្រ ធិរាជឫទ្ធិរឹងកន្លង
និរនេសអស់ក្សត្រផង នឹងប៉ះប៉ុនស្មើគេដដៃ ។
ស្តេចថ្កើងព្រះសក្តា ជាឧឡារិកពេកក្រៃ
អស់ក្សត្រផងដទៃ ទាំងរយមួយមករន្ធា ។
ព្រះកេរ្តិ៍ខ្ពស់ចិញ្ចែង នរអ្នកស្ញែងខ្លាចចេស្តា
ថ្កើងបុណ្យទ្រង់ពលា ជាអនន្តពន់ប្រមាណ ។
៥ – ស្តេចមានអគ្គមហេសី សឹងជាតិក្សត្រប្រធាន
ទ្រង់រូបឆោមកល្យាណ ទ្រង់នរលក្ខណ៍សមសោភាស ។
នាមនាងកេសនី ធំលើសស្រីផងទាំងផ្តាស
ព្រះស្នំផុំពេញពាស ជាសម្រាប់មហាក្សត្រថ្លៃ ។
ទាំងប្រាំមួយម៉ឺនមាន រូបកល្យាណល្អប្រពៃ
គង់គាល់រាល់សព្វថ្ងៃ សឹងចោមរោមគាល់ជុំជិត ។
ស្តេចមានអនុជា ឯកអគ្គាព្រះបពិត្រ
នាមក្រុងអសុភមិត្រ មានចេស្តាពេកកន្លង ។
ជាមហាឧបរាជា គ្រងរដ្ឋាបុរីស្នង
ព្រះវរៀមរូមគតហ្មង គ្មានរង្កៀសព្រះហឫទ័យ ។
១០ – ក្សត្រពីរពង្សស័ក្តិសែង បុណ្យចិញ្ចែងចិញ្ចាចក្រៃ
ប្រាកដប្រកបជ័យ ឮខ្ទរទៅសព្វទិសា ។



ហេតុជាពុទ្ធង្កូរ ជាកំពូលលើសលោកា
និរនរអ្នកឯណា នឹងប្រៀបត្រឹមព្រះអង្គបាន ។
ប្រកបព្រះសម្ភារ បុណ្យត្រកាលពេកប្រមាណ
រុងរឿងរាជពិមាន ល្អប្រសើរឥតគណនា ។
រីឯនាមបុរី សន្ធឹតពីបុរា
បុរាណនោះនាមា ឈ្មោះចម្បាកបុរីវត្ត ។
ស្តេចគ្រងរាជរដ្ឋា រាស្ត្រប្រជាទុកទៀងទាត់
ភោគ្និ៍ផលផងច្រើនក្តាត់ កើតដោយបុណ្យព្រះចេស្តា ។
១៥ - ហេតុជាតិវង្សត្រកូល ជាអម្បរព្រះប្រាជ្ញា
សេពសាងបារមិតា ជាអនន្តពន់កន្លង ។
ទើបបានសោភិនី មុខមន្ត្រីព្រាហ្មណ៍ប្រាជ្ញផង
គាល់ហៅក្សត្រជាច្បង គង់ជាផ្លូវរាប់រៀងរាយ ។
រាជវង្សអង្គសេនា រាស្ត្រប្រជាសុខសប្បាយ
ដើរលេងកំរៀងរាយ សព្វគ្រប់ល្វែងសុខក្សេមក្សាន្ត ។
និរទោសនិរទុក្ខា និរភយាមកបៀតបាន
សត្រូវសោគពុំហ៊ាន សឹងតែកោតខ្លាចសម្ភារ ។
បន្ទាយប្រាំពីរជាន់ ខាំងខេត្តខណ្ឌដោតដោយទ្វារ
មណ្ឌលគួរជាសជា ដាំកញ្ចក់ភ្លឺច្រវាត់ ។
២០ - មេរៀមរៀបរៀងរាយ ដោយនាងច្រាលប្រងប្រយ័ត្ន
កំណាន់ងាររទៀងទាត់ ចាំក្រវែលសព្វមាត់ ។

បញ្ចាបញ្ចាំ ថ្កោលគយឃ្លាំសព្វទិសា
គោះគងយាមនាឡិកា មានកំណត់កំណាន់ស្រាប់ ។
មេរៀមដាក់ដោយប៉ម រៀបប្រឈមសឹងផ្គួផ្គាប់
សំញែងតែងសម្រាប់ ឲ្យរុងរឿងយសសក្ដា ។
ស្ដេចគង់ប្រាង្គប្រាសាទ ល្អស្អាងស្អាតសមសោភា
បោសបិទសុវណ្ណា ក្លីវផ្កាលពន់ពេកក្រៃ ។
សឹងមានភ្លឺប្រសព្វ គ្រប់មណ្ឌបដោយទ្វារនៃ
ឆើតឆាយពេកប្រពៃ យល់រស្មីភ្លឺព្រោងព្រាយ ។
២៥ - កំពូលសមកម្ពស់ រៀវស្រួចស្រស់យ៉ង់យល់ឆ្ងាយ
ប្រាំពីរូតរៀងរាយ គ្រចាស់ចែងយល់រស្មី ។
កញ្ចក់ដាំគញ្ចាំង ភ្លឺទ្ទាំងវ័ត្ថមន្ទីរ
ដាសដាំដាក់ដោយភ្លឺ ក្បាច់ចម្លាក់ដាក់ដកចន្ទន៍ ។
សឹងឆ្លាក់ជារូបគ្រុឌ ទ្រប្រាកដប្រកបកាន់
នាគរាជព័ទ្ធពេនព័ន្ធ យល់សុទ្ធសាធរស់វិស័យ ។
ឆ្លាក់ជារូបកុម្ភណ្ឌ ដាក់ដោយខាន់ឡែកទីទៃ
សម្បើមសម្បាក្រៃ ហាក់ដូចនឹងប្រឹងឈានឈរ ។
លតាវល្លិពេនពង់ ជាពងហង្សមាសបវរ
ក្លែកក្លាយជាកិន្នរ កាន់គ្របកបទុមា ។
៣០ - ក្នុងក្អត់សែមសៀតសឹក លេចទៅមកសឹងទងផ្កា
សមនឹងវល្លិលតា បិទសុវណ្ណមាសមណី ។



ដាំដាសកញ្ចក់ចែង ភ្លឺស័ក្តិសែងផ្លេកនតី
ពព្រាតព្រាយរស្មី យល់ពព្រោងឯវេហាស៍ ។
មើលម្ដងហាក់ដូចស្ថាន សួគ៌វិមានត្រៃត្រឹង្ស
ស្រាលស្រុះចុះមកណា នៅផែនដីយល់វិសាល ។
ទំហំសមកំពស់ ស្រៀវស្រួចស្រស់ល្អត្រកាល
ត្រដែតត្រដូចដាល ស្លឹកខ្នុរខ្ទាប់ពលរូតរម្យ ។
ជហ្វាមុខរាហ៊ុពល់ ដងក្ដារទល់ជាមុខព្រហ្ម
ទ្រង់គ្រឿងល្អសក្តិសម ទាំងគាងឃ្វាងឆើតឆាយណា ។
៣៥ - កែមកែវមណីរ័ត្ន ប្រុះប្រិកិតដាំដោយពណ៌
រំលេចរាយរៀងរាល់ យល់ត្រចង់ត្រចះចែង ។
រស្មីប្រុះប្រាកដ ប្រកបសុទ្ធមាសទឹមទែង
ដាសដាំសមស័ក្តិសែង បទុមរាគរ័ត្នមណី ។
ស្វប្យកាន្តពេជ្រប្រពាឃ រ័ត្នរាគពលចែងរស្មី
មរកតទទឹមពិ ទូរ្យពិទាយនីលនៃបនិត្យ ។
រស្មីភ្លឺចែងចាំង នាទីន័ងមាសបោសបិទ
រចនាល្អពិចិត្រ សួស្ដីសុខសល់សមសោភា ។
មន្ទីរទិព្វបន្ទំ សឹងសួស្ដីសមរាជអាសនា
ទែនកែវរ័ត្នវេខា ស្វេតច្ឆត្ររ័ត្នភិរម្យ ។
៤០ - ពិតានដេរដាសដោម ទាំងកន្ទ្រាមតាឱលំ្យ
បើកបាំងទាំងបន្ទំ ពិតានមាសសួស្ដីសោភ័ណ ។

ត្រកាលអស្ចារ្យចែង    នរអ្នកស្វែងមើលមិនឆ្អន់
មិនផ្អែកនេត្រគយគន់    កោតសម្ភារព្រះបារមី ។
មើលមិនបាក់នគរ    ចម្បាកវររាជបុរី
ហាក់ដូចស្ថានសួគ៌ស្រី    ពិមានមាសត្រៃត្រឹង្សា ។
សុទ្ធសាធសមស័ក្តិសែង    លួចិញ្ចែងលើសលោកា
ប្រកបព្រះចេស្តា    យល់អនេកអនន្តភ្ញាត់ ។
មានឃ្លាំងច្រើនណាស់ណាន់    ក្រៃលែងពាន់ពេញប្រកិត
កំណាន់ងារទៀងទាត់    ចាំរក្សាជាប្រក្រតី ។
៤៥ - មណីរ័ត្នច្រើនពិស្តារ    សឹងច្រះចារដាក់ដោយទី
មាសប្រាក់សោភិនី    រកោសេយ្យព័ស្ត្រផងទាំងឡាយ ។
ដាក់ឃ្លាំងទុកសម្រាប់    អស់ទាំងទ្រព្យផងតែងចាយ
សឹងដាក់ឃ្លាំងរាល់រាយ    រៀងជាជួរក្រៅវាំងខណ្ឌ ។
មានទ្វារហ្លួងស័ក្តិសែង    ផ្លាត្រឡែងកែងពេនព័ន្ធ
ពាយពាន់ជាណាស់ណាន់    រៀបប្រកិតផិតកុះករ ។
មានរោងរាជគជា    រោងអស្សាពាហ៍រាជអស្សតរ
មានរោងរថបវរ    ជាំមរកតកែវស្វរ្យកាន្ត ។
រស្មីភ្លឺច្រវាត់    ឆ្លុះវង្កាត់ហាក់រហាន
ពានរថសួគ៌ពិមាន    មកទុកនៅនាផែនដី ។
៥០ - ភ្ញាក់ងារផងណាស់ណាន់    នៅប្រកាន់មណ្ឌលទី
រក្សាសព្វរាត្រី    សឹងបន្លាស់ដោយមុខងារ ។



សម្រាប់មហាក្សត្រក្សាន្ត    ឃ្លាំងធនធានសព្វប្រការ
ប្រកិតនេរជាសជា    ផិតផុំវាំងទីទូលាយ ។
ព្រះបាទក្រុងសុភមិត្រ    ធិរាជឫទ្ធិរុងរឿងសាយ
អស់រាស្ត្រផងទាំងឡាយ    សឹងសរសើរព្រះបារមី ។
ស្តេចសោយរាជ្យស្កប់ស្កល់    សុខស្ងួស្តីសល់សម្រឹទ្ធី
ក្សត្រានុក្សត្រី    លើសកន្លងលើលោកា ។
ដូចព្រះចន្ទ្រចែងជ្រះ    ភ្លឺស្រឡះឯវេហាស៍
ពពួកអស់តារា    សឹងចោមផុំជាបរិវារ ។
៥៥ - ព្រះអង្គជាឯកពជ    ស្តែងអំណាចព្រះសម្ភារ
ព្រះស្នំស្រីស្រីង្គារ    ច្រើនណាស់ណាន់ពន់ពេកក្រៃ ។
សឹងមានរូបពិសី    ហាក់ដូចស្រីសួគ៌ាល័យ
លួលួះគួរបេតី    ស្និទ្ធសេពសមបញ្ចិន្ទ្រិយ ។
គង់គាល់ក្សត្រជាច្បង    លើសកន្លងលែងលោកិយ
សេពសុខនឹងអស់ស្រី    ទ្រង់ក្រសាលសព្វទិវា ។
កាលនោះអគ្គមហេសី    កេសនីរជាយា
នាងនាថទ្រង់គភ៌ណា    គ្រប់បរិបូណ៌ខែទៀងទាត់ ។
ប្រសូត្ររាជបុត្រា    ព្រះបិតាប្រតិព័ទ្ធ
ថ្នាក់ថ្នមរួមផ្គេកផ្គិត    ឲ្យមេនំជួយរក្សា ។
៦០ - ភីលៀងច្រៀងបំពេ    បុត្រស្និទ្ធស្នេហ៍ស្ងួនសង្សារ
អក់រយាយស្រីស្រីង្គារ    សឹងចោមផុំជាប្រក្រតី ។

វត្តរាជកុមារ សមសោភាអស់ឥន្រ្ទិយ
ដូចមាសទើបឲ្យដី ល្អត្រកាលឥតគណនា ។
ក្សត្រានូវក្សត្រី ស្ងួនមេត្រីឱរសា
ស្តេចឲ្យនាមហៅជា ចៅជ័យសែនរាជកុមារ ។
លុះអម្លងតិចទៅ បុត្រចមចៅស្ងួនព្យាបាល់
ដឹងក្តីសព្វប្រការ បានព្រះជន្មបីឆ្នាំគត់ ។
ក្សិណនោះឯក្សត្រី កែសនីបវរវ័ត្ត
នាងទ្រង់គត៌ទៀតថ្វាត់ បរិបូណ៌គ្របទសមាសា ។
៦៥ - ប្រសូតព្រះរាជបុត្រ ប្រុសប្រាកដល្អសោភា
ស្តេចថ្នមបុត្រពុំងា ថើបថៃអស់អង្គឥន្រ្ទិយ ។
សារដៃស្រីស្រីង្គារ ស្នំក្រមការរួមបេតី
ស្រឡាញ់បុត្រភ្ញាប្រិយ បីថ្នាក់ថ្នមគ្រងរក្សា ។
ស្តេចឲ្យនាមបុត្រវ័ត្ត ហៅជ័យទត្តរាជកុមារ
គីល្បេងចាំព្យាបាល់ តែងប្រឡែងឱរសា ។
បុត្រពីរពេញសំឡាញ់ ថ្នមអស់អញសព្វទិវា
ក្សត្រីនូវក្សត្រា សោយសម្បត្តិសម្បូណ៌បុណ្យ ។
៦៩ - ទ្រប់ទសពិធរាជធម៌ ជាអស្ចារ្យប្រសើរលន់
ស្តេចឲ្យទានទ្រព្យធន ជាប្រក្រតីសព្វទិវា ។

**មធពំនោល**

១ - កាលនោះឯក្រុងព្រះមហា ឧបរាជអនជា- ធិរាជបរមបពិត្រ ។
ស្តេចគង់កម្ពុងឋានបិត មន្រ្តីព្រាហ្មណ៌គ្រឹទ្ធ គង់គាល់សម្តេចនរបតី។



ស្តេចរំពឹងបុរី បុរាណវរណី ជំនុំនឹងអស់សេនា ។
ចំពុកឯមហាក្សត្រា សុទ្ធសឹងក្លៀវក្លា ជំនឿជំនិតភក្តី ។
៥ - ថាព្រះរៀមរាជចក្រី ស្តេចពុំប្រណី ឲ្យរាជសម្បត្តិរដ្ឋា ។
ស្តែងស្តេចពុំពិចារណា សោយសុខសក្កា ឥសូរសម្បត្តិយូរលង់ ។
ម្តេចឡើយពុំគិតឯអង្គ អញអនុជស- ង្ស្សារសត្វឯកឧទរា ។
គំណជំនៀលនិន្ទា ក្សត្រឥតចេស្តា នឹងជាប្រយោជន៍កលអ្វី។
ពុំបានគ្រប់គ្រងបុរី បុរាណវរណី គំណគំណាងបិតា ។
១០ - ស្តេចទ្រង់ព្រះក្រោធមហិមា ស្មើរផ្លាយឱរា រន្ធត់ទាំងព្រះហឫទ័យ ។
ហេតុកម្មពោធិសត្វថ្លៃ តាមទាន់អង្គឲ្យ ពិតពុំឃ្លាតឃ្លាឡើយណា
នឹងឲ្យស្តេចរងវេទនា គម្មរជាឃា នូវរាជបុត្រាពីរពង្ស ។
កាលនោះមន្រ្តីក្រាបក្រុង បង្គំទូលអង្គ ព្រះឧបរាជឫទ្ធី ។
បពិត្រព្រះបាទនរបតី ឥសូរសិរសី ប្រសើរលើសលែងលោកា
១៥ - រាជសម្បត្តិរដ្ឋា គួរតែក្សត្រា គ្រប់គ្រងរាស្រ្តរាជវរណី។
ទើបត្រូវត្រិត្យក្រមសេចក្តី ដូចរាជសវនីយ៍ ពុំចេរទ្រង់ព្រះចិន្តា ។
ចំណេរលង់យូរហើយណា រាជរដ្ឋា សមបានកុមារពីរពង្ស ។
ស្តេចស្តាប់សារសព្ទរាជវង្ស ទើបទូលព្រះអង្គ ព្រះឧបរាជរាជា ។
ស្តែងស្តេចព្រើសព្រមចិន្តា បន្ទូលត្រាស់ថា ហៃរាជមន្រ្តីពលផង ។
២០ - ចូររៀបគជសារកន្លង សេះសឹកគ្រឿងចង នូវពលចំពុកយោធា ។
មន្រ្តីក្រួញក្រាបលុគលា រួសរៀបសេនា ប្រដាប់នូវគ្រឿងចំបាំង។
សុទ្ធសឹងពលពាលខ្លោះខ្លាំង អាងអួតប្រណាំង ប្រយុទ្ធដណ្តើមគេជនៃ។

ស្តេចឲ្យបោះពលក្រាស់ក្រៃ ដោយចំពូកនៃ កំណាន់កំណត់យោធា ។
ស្រិតស្រាលសុទ្ធសឹងហានក្លា ធាត់ធំក្រទា ក្រអួនមាំមួនក្រអាញ ។
២៩ សឹងមានជំនឿសឹកសាញ ជោគជ័យជាក់ជាញ ប្រកិតអាវុធរាលរាយ ។
សឹងកាន់ពលដប់មួយនាយ ចំពូកលែបលាយ ទាហានជាញជិះអស្សពាហ៍ ។
មាត្យមុខមន្ត្រីយោធា លើកពលត្រៀបត្រា អនេកអនន្តក្រាស់ក្រៃ ។
ស្រេចស្តេចឲ្យគោះគងជ័យ លាន់ឮប្រពៃ កក្រើករំពើកពសុធា ។
ក្បួនត្រៃស្គរជ្វា ស្គរទ័ពស្គរងារ ស្រួលស្រើបរំជើបអឺងកង ។
៣០ ឆោឡោស្រែកហោបីដង សូរសព្ទរំពង ស្នើរត្ថកបុរីរាជស្ថាន ។
ស្តេចគង់គជសារហាវហាន ខ្ពង់ខ្ពស់ទាហាន ចូលចោមពន្លឹកក្រាស់ក្រៅ ។
រាស្ត្រទាសភិតភ័យចៅរ៉ៅ ពកូនពចៅ ជញ្ជូនទ្រព្យរត់រពាយ ។
សឹងរត់ចូលក្នុងបន្ទាយ ខ្លះរត់ចេញឆ្ងាយ ពឹងពួនសព្វព្រៃព្រឹក្សា ។
មន្ត្រីឡើងទូលក្សត្រា ថាមានសឹកសា ហាវហានចូលចោមបុរី ។
៣៩ បពិត្រព្រះបាទនរបតី ឥស្សរសិរសី ប្រសើរលើសលែងលោកា ។
ក្បិតមានឧបរាជអនុជា ទ្រស្តក្បត់ក្សត្រា ដណ្តើមយករាជសម្បត្តិ ។
ស្តេចស្តាប់មន្ត្រីទូលថ្វាត់ ទ្រង់ព្រះក្រោធក្តាត់ រន្ធត់ទាំងព្រះអង្គា ។
ក្តៅថ្លើមដង្ហើមផ្សាយផ្សា ស្នើរបែកឱរា ព្រះនេត្រប្រាលដូចអគ្គី ។
ខំប្រឹងទប់ព្រះស្មារតី ហេតុពង្សពោធិ- សត្វសាងសីលសម្ភារខ្ជាប់ ។
៤០ ស្តេចឈ្វេងគម្រិះគួរគាប់ ទោសទៀងក្បិតទ្រព្យ សម្បត្តិសម្បូណ៌សក្កា ។
ស្តេចគិតសង្វេគអនិច្ចា រូបំអនត្តា ឥតខ្លឹមឥតសារសូន្យសោះ។
សង្ខារបណ្តាលទោសស្មោះ ឥតត្រើយឥតកោះ ពំនាក់ពំនឹងរូបបាន ។
យង់យល់តែសីលនិងទាន ទៀងទើបនាំប្រាណ រួចចេញពីចតុរាបាយ ។



៤៤ ស្តេចឈ្វេងយល់ធម៌សព្វសាយ ហេតុព្រះប្រាជ្ញប្រាយ ពន្លឺកពន្លឺលោកា ។

**បទភាគគតិ**

២២ - កាលនោះមហាក្សត្រ បើកបន្ទូលថ្វាត់ នឹងរាជអមច្ចា
ថាមហាឧបរាជ អំណាចចេស្តា នាំពលយោធា
ចូលចោមបុរី ។
បើយើងតតាំង កងទ័ពចេញច្បាំង ឲ្យយល់ឫទ្ធី
ក្រែងកើតកង្វល់ អម្ពល់សេចក្តី អាសូរប្រណី
រាស្ត្ររដ្ឋទាំងឡាយ ។
នឹងកើតផ្សាក្តៅ ព្រាត់ប្រាសកូនចៅ ហិនហោចខ្ចាត់ខ្ចាយ
ស្លូតស្លាប់សូន្យសោះ ហេតុនោះអញណាយ មិនឲ្យអន្តរាយ
ជនជាតិឡើយហោង ។
២៥ - បើអនុជគាត់ ចង់យកសម្បត្តិ ឥស្សរគ្រប់គ្រង
អញនឹងចៀសចាក លះលែងចេញផ្គង ទៅនៅដោយដង
ព្រៃព្រឹក្សហេមពាន្ត ។
ស្តេចបន្ទូលទៀង ប្រែព្រះភក្ត្រផ្ទៀង កាន់នាងកល្យាណ
អយ៉អគ្គមហេសី ក្សត្រីប្រធាន សំណេះសង្សារ
ប្រាយប្រាប់ជាយា ។
ប្អូនអើយឥឡូវ មានរាជសត្រូវ មោះមកប្រាថ្នា
ដណ្តើមសម្បត្តិ រម្យរដ្ឋសីមា ចូលចោមហើយណា
ពន្លឹកក្រាស់ក្រៃ ។

គឺព្រះអនុជា លោភលន់មោហា ចិត្តចោរកាចក្រៃ
ទ្រុស្តក្បត់យកពង្ស ពុំខ្លាចឡើយនៃ តាំងទ័ពទីទៃ
យុទ្ធយករដ្ឋ ។

ប្អូនអើយអង្គអញ លាកលាចរចេញ ទៅនៅព្រឹក្សា
សាងសីលបរិសុទ្ធ លំអុតអាត្មា ស្ងឹងស្ងាធីភាវនា
លះលាភបាបបង់ ។

៣០ - ក្សិណនោះនាងនាថ ស្តាប់ព្រះចមជាតិ នាងភិតហ្វឹនហ្វង់
ហឫទ័យចំប្រប់ ស្ទន្យសព្វអស់អង្គ ខំតែតម្រង់
ស្មារតីនិត្យនៅ ។

នាងនាថវរភិទ ក្រាបក្រោមព្រះបាទ ពោធិចមចៅ
គរគក់ឱរា កក្រ្កាប្រាលឆ្នៅ ទ្រូងត្រតក្តាត់ក្តៅ
ទួញទូលថ្លឹងថ្លែង ។

បពិត្រអម្ចាស់ ខ្ញុំភិតភ័យណាស់ ម្តេចស្តេចលះលែង
ចោលខ្ញុំកំព្រា ខ្លោចផ្សាម្នាក់ឯង ខ្ញុំធ្លាប់រួមរែង
បម្រើសព្វថ្ងៃ ។

បើស្តេចចៀសចាក ឲ្យប្អូនលំបាក សមនឹងក្សិណក្ស័យ
ប្អូនសុំទៅផង រួបរងក្សត្រថ្លៃ ប្រការម្តេចក្តី
ពុំលែងឡើយហោង ។

នៅថ្វីអសារ ស្ទន្យសោះឥតការ លំបាករស់រង
ទុក្ខទៀងប្រាកដ បទបាត់ព្រះបង ព្រះរៀមស្នេហ៍ស្នង
ធ្លាប់រួមមេត្រី ។



៣៩ - ស្តេចស្តាប់ព្រះប្អូន ហឫទ័យសោះសូន្យ សោយសោកសែនទ្វី
អនាថអាណិត គន់គិតទេពី ឱបអង្គប្អូនស្រី
បើកបន្ទូលថា ។

ឱប្អូនប្រសើរ មាសមិនដែលដើរ ត្រាច់ដោយមាគ៌ា
នឿយហត់ហាលថ្ងៃ ក្នុងព្រៃអធ្វា សព្វសត្វហិង្សា
សាហាវទ្រើសយ្នង ។

បងមហាប្រណី អាសូរប្អូនស្រី ស្រីស្រស់ឥតគ្នង
មិនដែលពើបព៉ះ ប្រទះសត្វផង ពល់រៀងដោយដង
ព្រៃព្រឹក្សស្មសាន ។

នាងនារីរ័ត្ន ស្តាប់ព្រះរៀមឃាត់ នាងសោកប្រះប្រាណ
ដួលដល់សន្លប់ ស្ទន្យសព្វនៅស្ថាន ព្រះរៀមក្សត្រក្សាន្ត
រួសរកគង្គា ។

ក្សង់ក្សិតព្រះភក្ត្រ នាងនាថភ្ញាក់ភ្ញាក់ សែនសោយសោកា
ណាល់ណាស់ឥតស្បើយ ល្ហិតល្ហើយទុក្ខា ផលនៃត្រធារ
ទន់ទាំងហឫទ័យ ។

៤០ - នឹងឃាត់ពុំបាន នាងនាថកល្យាណ សង្វាវថ្លើមថ្លៃ
ទ្រង់កន្សែងសោក អរោក្សពេកក្រៃ បន្ទូលថាហៃ
ប្អូនមាសកំសត់ ។

ចូរនាងម្ចាស់ រួសរៀបយាត្រា តាមក្តីទុគ៌ត
វេពពីព្រេង យើងឯងប្រាកដ ដូចដល់កំណត់
ចៀសចាកពុំបាន ។

ក្សត្រពីរព្រះអង្គ សឹងតែទួញទ្រង់ កន្សែងប្រះប្រាណ
សែនសោយសោកសោះ ស្រណោះរាជស្ថាន ទើបក្សត្រប្រធាន
សែនចាកបន្ទំ ។

ពបុត្រទេ្វហារ សែនសោយសោកា ទ្បេងទួញយោបំ
គរគក់ឱរា ឈឺផ្សាអួលក្រំ កម្លុងដាស់ទុំ
ផ្តួកផ្តើលរជោ ។

ព្រះស្នំស្រីង្គា សឹងសោកភូបាល ទ្រហឹងនោទ្បោ
អនាថអាណិត គន់គិតពង្សពោ ធិសត្វសេដ្ឋោ
ចេញចាកបុរី ។

៨៥ - ស្តេចពបុត្រា ជ័យសែនកុមារ នាងនាថនារី
ពចៅជ័យទត្ត បុត្រវ័ត្តភ្ញាប្រិយ ផលនេត្រទាំងទ្វី
ស្រក់ដោយមាត៌ា ។

នាងទួញបណ្តើរ ស្រីវ័ត្តប្រសើរ ខំយាងយាត្រា
ចូលក្នុងព្រៃព្រឹក្ស ពន្លឹកអធ្វា នាំងទួញអនាថ៍
អាណិតឥតស្បើយ ។

ស្តេចលោមព្រះប្អូន ហឫទ័យសោះសូន្យ ថាឱប្អូនអើយ
វេរាព្សេងព្រេង យើងឯងផ្តល់ហើយ ព្រលឹងបងអើយ
កុំសោយសោកា ។

ចូរប្អូនមាសអត់ តាមប្តីកំសត់ ខំចរយាត្រា
ក្រែងអស់មនុស្សផង យល់បងហើយវា ទៅប្រាប់អនុជា
នឹងតាមមកនៃ ។



ក្រែងគេចោមចាប់ យកទៅសម្លាប់ ជីវិតក្សិណក្ស័យ
សេនាគេស្រាប់ ប្រដាប់ច្រើនក្រៃ ធ្វើសង្គ្រាមជ័យ
យករាជសម្បត្តិ ។

៩០ - ប្អូនអើយយើងក្រ យើងរស់រត់រក៏ ពឹងពួនព្រៃស្ងាត់
ព្រៃព្រឹក្សស្មសាន រុករានដើរកាត់ នៅនិក្សដូចសត្វ
រសោះគេយង់យល់ ។

ព្រះអង្គនាំនាង ខំដើរយាសយាង ដោយដងថ្នាក់ថ្នល់
ចូលក្នុងព្រឹក្សា យោនយានសាយសល់ ស្រងូតទុព្វល
ស្រងាត់អធ្វា ។

ប្រទះនឹងសត្វ ក្រាស់ក្រៃពេកក្កាត់ ដើរដោយហ្វូងវា
ខ្លះឈប់ខ្លះឈរ រកបរិភោក្តា ខ្លះខ្លាចរត់រា
ដាលដេញចេញឆ្ងាយ ។

រហាសរមាំង ប្រើសទ្រាយខ្ទឹងខ្លាំង ទន្សោងទន្សាយ
ធចកស្វានស្វា ប្រមាឈ្លូសទ្រាយ គោកគោលេចលាយ
ក្រឹបីថ្វូចថ្វរ ។

ក្បេងកាល់ញីញង ងើយងផ្សេងផ្ទង ប្រែប្រឹងអួគអរ
ខ្លះរត់រត់ចេញ ដាលដេញខ្មាយខ្ទរ ខ្លះឈ្មះងើយង
រាងរូបស្តឹមស្មេ ។

៩៥ - ដំរីទ្រហឹង ចិញ្ចាចអឺអឹង រួសរត់រិលរេ
ជាញផល់ឥតក្រែង គគ្រេងទាំងព្រៃ ក្បេងគួរក្រាស់ក្រៃ
ដើរដោយហ្វូងវា ។

នាងយល់អស់ម្រឹគ ដេរដាសគគឹក ភិតភ័យតក្កមា
ចំប្រប់អស់អង្គ ទូញទ្រង់សោកា បីបុត្រពុំងា
វត់រូចចេញចរ ។

លុះព្រឹកស្រេចស្រាង សុរិយាបំព្រាង ទើបព្រះភូធរ
ឈរឈប់សម្រាន្ត កំសាន្តសាទរ បេះផលបានប-
រិភោគភ័ក្ខនានា ។

សោយស្រេចពុំលង់ ព្រះអង្គពីរពង្ស នូវរាជកុមារ
ត្រាច់ត្រង់ព្រៃព្រឹក្ស ពន្លឹកអធ្វា ពុំដឹងមាគ៌ា
ដើរដោយសៅដៅ ។

រុកពានត្រាច់កាត់ ឮតែមាត់សត្វ យំក្នុងព្រៃជ្រៅ
ក្រៀមក្រំកត្រា ឱពអួលក្តៅ ក្សត្រក្សាន្តចមចៅ
នូវនាងជាយា ។

៦០ - នឿយណាស់ល្ហិតល្ហៃ ពបុត្រថ្លាថ្លៃ ទាំងពីរអង្គា
លន្លង់លន្លោច គ្រមោចកំព្រា ឥតមានអ្នកណា
កំដរឡើយហោង ។

ស្តេចដើរខ្មីឃ្មាត ខិតខំសង្វាត ព្រះបាទពុរពង
ដាលដូចឡើងឈាម រអាមក្តាត់ហោង ក្សត្រពីរច្បាស់ច្បង
លំបាកពេកក្តាត់ ។

ស្វែងស្តេចរុកពាន ត្រាច់ព្រៃហិមពាន្ត ពុះពាររានកាត់
ព្រៃព្រេចបន្លា លតាវល្លិព័ន្ធ គ្រឡុកគ្រឡាត់
ទន្លាប់ទន្លា ។



ស្រគំជ្រៃជ្រៃ គ្រស្ងួលល្ហុតលៃ សណ្តាន់សណ្តា
ដកពដកពាយ ក្រវាន់គ្រៀលស្វា ក្រួចក្រាយពភ្លា
ស្រឡៅស្រឡី ។

សំពោងសំរោង ស្តុកស្តុរអង្គ្រង ខ្លឹងក្តម្ពស្ទួរភី
ទ្រមូងទ្រមូច ពោធពួចកាកី កាកែសន្ទួនស្រី
ចេកទេសយុថ្កា ។

៦៩ - គ្រៀកគ្រាចភ្លូង ច្រេសជ្រួយដើមដង អង្កោលក្រស្នា
រលួសរលោះ លំពស់ឆាំឆា គ្រើលគ្រង់ស្នាចស្នា
ក្របីកប្បាស ។

ពពេលពពួល ស្រមូវស្រមូល ស្រម៉អង្គាស-
ដីផុះដោយពណ៌ រៀងពាល់ពិលាស លៀបលោទដេរដាស
រំដេញរំដួល ។

ម្លិះរូតម្លិះលា ចំប៉ីចំម្បាំ រំចេករំយោល
រីករុះបុប្ផា ផលាដង្កោល ដាលផុះដោយទួល
ទន់មែកព្រឹក្សា ។

ព្រះអង្គនាំនាង សន្សឹមយាសយាង ដោយផងបព្វតា
ព្រៃព្រឹក្សស្រោងស្រឹង ទ្រឈឹងសាខា មែនមានបក្សា
អាស្រ័យទីមទំ ។

ស្វរសព្ទក្រសារ គ្រៀលក្រួចទទា ទោមទុងទាបទំ
ចចាតចៀបចាប ព្រៃព្រាបមៀមមុំ ទៀវទោចច្រឡំ
ស្រដាត់អធ្វា ។

៧០ - រប៉ាលគោកតាវៅ  ចចាតស្វិតចៅ  យាសយំឆ្លើយគ្នា
កងកេងអង្គត់  ខ្មៅសុទ្ធសារិកា  កែវកោកិលា
មយុរាហោមហង្ស  ។
ព្រះពង្សពោធិ៍  នាំនាងម្ចាស់ស្រី  ពបុត្រពីរពង្ស
យល់សត្វបក្សី  ឈ្មោលញីគូគង់  ពាំភ័ស្តុផ្ចិតផ្ចង់
បញ្ចុកកូនវា  ។
៧២ - នាងទកមៀងមើល  ទៀងទួញបណ្តើរ  ដោយផ្លូវមាគ៌ា
លន្លង់លន្លោច  ត្រមោចកំព្រា  តែប្អូនក្សត្រា
ស្រងាត់ទុព្វល  ។

## បទភុជង្គលីលា

នក្សត្រាថ្លៃថ្លាស្ងួស្តីសល់  គ្រាច់គ្រង់ដើរដល់  ជ្រងជ្រោះគិរី  ។
ម្លឹអរចង្ការទួលទី  ស្រះបោក្ខរណី  រះរាបរងថ្លា  ។
ព្រះអង្គពីរពង្សសោភា  នាំបុត្រពុំងា  ចុះស្រង់ភារី  ។
ស្រង់ស្រេចសម្តេចចក្រី  នាំបុត្រពិសី  ដើរដោយត្បូងខ្សាច់  ។
មើលផ្កាបុប្ផាស្រស់ស្រេច  បុបុស្សរំលេច  រីកវុះសាយសព្វ  ។
ចម្ប៉ាក្តាំងងាឈ្ងុញឈ្ងប់  ដោរដុចអ្នកអប់  ទាំងព្រៃព្រឹក្សា  ។
កាកែសចេកទេសយុថ្កា  ម្លិះរូតម្លិះលា  ខ្សឹងខ្សំសូរគី  ។
មហាហិង្គុប្រយង្គុំនូនស្រី  ស្រឡិតមាលតី  លាយលេចច្បាប្រាល  ។
លន្តៃពុតធ្លេរន្ទាល  រំចេកដាសដាល  ដុះដោយទីទួល  ។
ព្រឹក្សាបុប្ផាដង្គរ  ហាក់ដូចអ្នកព្យូរ  សំយុងយោនយាន  ។
គអុងគ្រាច់គ្រង់សព្វសាន  សៀងសូរហាន  ភ្លេងត្បូតន្រ្តី  ។



គ្រាច់ត្រីបផញ្ចាប់ក្លិនក្លី  កេសររីកថ្មី  ពិដោរសព្វសាយ  ។
ក្សត្រាថ្លៃថ្លារួសរាយ  សំណេះប្រាប់ប្រាយ  វត្តរាជក្សត្រី  ។
ស្តេចបេះប្រឡេះផលភ្លី  ឲ្យបុត្រទាំងពីរ  បរិភោគសោះឃ្លាន  ។
ស្តេចចរនាំវរកល្យាណ  គ្រាច់ក្នុងស្មសាន  ស្ងប់ស្ងាត់ជ្រងំ  ។
ដើរគ្រាច់លុះលេចព្រៃភ្នំ  វាលវែងធារធំ  ដល់ឆ្នេរនទី  ។
ព្រះមហាក្សត្រាក្សត្រី  សែនសោយសោកពី-  លាបលន់រន្ធត់  ។
ចរចេរតាមឆ្នេរសមុទ្រ  ពៀងពរាជបុត្រ  ទាំងពីរអង្គា  ។
ឈរឈប់ក្រោមម្លប់ព្រឹក្សា  ទៀងទួញថែថា  ឱគ្រានេះម្តង  ។
សមក្រកម្រក្លាត់ហោង  គ្មានទូកនឹងឆ្លង  ឲ្យដល់ត្រើយត្រាណ  ។
ក្សត្រីទេវីកល្យាណ  សោយសោកប្រះប្រាណ  លន្លោចឯកឯង  ។
នាងទួញទំនួញក្តែង ។  នាងគិតខ្លាចក្រែង  ពុំរួចជីវិ  ។
គិតបុត្រវិសុទ្ធទាំងទ្វី  គិតព្រះស្វាមី  សោយសោកឥតហើយ ។
ស្តេចថាពុំងាស្ងួនអើយ  បងយល់ច្នេះហើយ  ពុំយកប្អូនមក  ។
ឱស្ងួនខ្ទឹមខ្ចីនពន្លក  បងយកប្អូនមក  ឲ្យប្អូនអម្តេញ  ។
នាងទូលឥសូរសម្លាញ់  ទុក្ខខំវែងម្តេញ  សូវមកច្នេះណា  ។
គាប់ខុសស្លាប់រស់ផងគ្នា  តាមកម្មវេរា  ពីព្រេងនាយនៃ  ។
ព្រះមហាក្សត្រាថ្លាថ្លៃ  បន្ទូលថាហៃ  ព្រលឹងបងអើយ  ។
កុំនាងបារម្ភពេកឡើយ  ដារបងឯងហើយ  នឹងហែលចម្លង  ។
យកប្អូនខ្ទឹមខ្ចីនស្នេហ៍ស្នង  នានាំទៅផ្តង  ដាក់ដល់ត្រើយត្រាណ  ។
ទុកបុត្រពិសុទ្ធកល្យាណ  នៅអាយឲ្យខាន  ចាំនៅនេះណា  ។
សឹមបងវិលចរយាត្រា  យកបុត្រទៅហារ  វិលវិងទៅថ្កាន  ។

ផ្ទបផ្ទូននឹងស្ងួនកល្យាណ ម្ទូលបរិប្ទូណ៌បាន សីមយើងចេញចរ ។
នាងស្តាប់សាសព្ទភ្ទូធរ ស្រីវ័ត្តបវរ ទង្គឹះខ្លោចផ្សា ។
នាងនាថសញ្ជប់ភគ្រា គិតបុត្រទ្វេហារ ត្រមោចឯកឯង ។
ក្សត្រីទេវីចំបែង អ្វូលឱ្យវវែង ថៃថប់ពេកក្រៃ ។
នាងសោកអមោក្សអាល័យ បីបុត្រថ្លើមថ្លៃ បំបៅស្រេចហើយ ។
ផ្តាំថាពុំងាម្តាយអើយ ម្តាយឆ្លងទៅត្រើយ នាយនឹងបិតា ។
ចូរចៅចាំនៅនេះណា មើលប្អូនឲ្យជា កុំឲ្យយំឡើយ ។
កម្មឯងពីព្រេងផ្តល់ហើយ ធ្វើម្តេចស្ងួនអើយ ចៀសចាកពុំបាន ។
ផ្តាំស្រេចសម្តេចក្សត្រក្សាន្ត ពនាងកល្យាណ ហិចហែលច្រៀវច្រែ ។
កណ្តាលប្រវាលផលស័យ ស្តេចពុំគិតភ័យ នឹកខ្លាចមច្ឆា ។
សមុទ្រវន្តមហិមា រលកផលសា បោកបែងផ្កាត្រែង ។
សន្ទឹកពន្ទឹកគគ្រេង គគ្រាំបែកផ្សែង អ័ព្ទអស់ទិសា ។
ព្រះពាយផាត់ផាយគង្គា ពន្លឹកមហិមា ស្ទូរសព្ទរំពង ។
ក្រពើលលើហែលឆ្លង មករពិន្ទង បបែលឆ្វាមឆ្លាំង ។
រេរហែលហាសំកាំង សឹងគិតភ័យខ្លាំង ខ្លាចព្រះបារមី ។
ព្រះអង្គពុំផពង្សពោធី ខ្លាំងស្មើដំរី ប្រាំពីរមហិមា ។
ដូចអង្គកុជង្គនាគា ទ្រង់នូវពលា ឡើងលើផលធី ។
ស្តេចឆ្លងចម្លងទៅទី នានាំប្អូនស្រី ហិចហែលសំដៅ ។
ឆ្ពេរឆ្ពេរសមុទ្រជ្រាលជ្រៅ ទឹកថ្លាយង់ខ្មៅ គួរស្បើមមហិមា ។
ហេតុបុណ្យលើសលន់ក្តក់ណា បានសាងប្រាថ្នា សរពេជ្ជជិនស្រី ។
ព្រះមហាក្សត្រាធិបតី នានាំមហេសី លុះដល់ត្រើយត្រាណ ។



ស្តេចចរនាំវរកល្យាណ ឡើងឈប់សម្រាន្ត ទិទ្ទូលថ្នាក់ថ្នល់ ។
គិតបុត្រពិសុទ្ធស្ទូស្តីសល់ នេត្រាជោរផល ទ្ទូញទៅបុត្រា ។
នឹងថ្លែងសម្តែងកាលគ្រា កាលមហាក្សត្រា នាំនាងទេវី ។
ហែលឆ្លងចម្លងផលធី ក្រោយនោះមាននេ- សាទពីអង្គា ។
ស្ទុះស្វែងលះលែងសីមា ឪនអ៊ុំនាវា ប្របឆ្នេរជលធី ។
ព្រាហ្មណ៍ព្រានដឹងដាននទី ចរចេញរកស៊ី ស្ទាក់ស្ទួចមច្ឆា ។
ទាំងយប់ព្រលប់សន្ធ្យា ទៅទៀបបុត្រា ក្សត្រថ្លៃច្បាស់ច្បង ។
ព្រានព្រៃវាងវៃចូលផ្លូង យល់បុត្រច្បាស់ច្បង នៅឆ្នេរជលសា ។
ព្រានគិតក្នុងចិត្តឯងថា អេះកូននរណា មកនៅនេះនៃ ។
ភ័ព្វអញចរចេញមកព្រៃ ឥឡូវលាភជ័យ ដល់ដូចប្រាថ្នា ។
គួរះសំណេះចរចា ជាកូននរណា មកនៅទូរទី ។
ជាខ្មោចអសោចិ៍អប្រិយ ឬយក្ខិនី ប្រែប្រាណកាឡា ។
ឬជាទេវតានៅនា តែងចាំរក្សា ស្ថិតស្ថានគិរី ។
អម្លុងយូរលង់អំពី ដើមរឿងមកក្តី ពុំដូចច្នេះណា ។
ទើបព្រានសាកសួរទៅថា ចៅមកពីណា ទាំងយប់រាត្រី ។
ម្តាយចៅនិត្យនៅបុរី បុរាណទិសទី តំបន់ស្ថានណា ។
អ្នកស្តាប់ពុំប្រាប់សោះសា ពុំបែរតគ្រា ខ្លាចព្រានឃាឃី ។
អ្នកគង់ឱបអង្គសិរសី តិតញ៉រឥន្ទ្រីយ រន្ធត់អង្គា ។
អ្នកគិតក្នុងចិត្តឯងថា ព្រាននេះពីណា យល់អង្គក្តី ។
អ្នកខ្លាចអំណាចដើម្បី នឹងហ៊ានស្រដី ប្រាប់ព្រានឡើយណា ។
ស្ងាស្ងប់ចំប្រប់អង្គា ពុំហ៊ានចរចា ស្ទូរសេងវាទី ។

៧៥- ព្រានឆ្លល់ក៏កលស្រដី ប្រលោមពាក្យពី- រោះរូចចរចា ។
ចូរចៅមកនៅនឹងតា តានឹងរក្សា ទុកជាបុត្រហោង ។
កុមារពិសាលស្នេហ៍ស្នង វែងភិតកន្លង កន្លែងសោតសល់ ។
អ្នកសោកអមោក្យជោរដល់ ទៀងទួញទៅដល់ រកព្រះជននី ។
ផ្កាក្មេងពុំដឹងសេចក្ដី វែងជាភិតពី- លាបលន់ឥតស្បើយ ។
៨០ ព្រានព្រឹទ្ធចូលផិតទៅហើយ ពិតពុំលង់ឡើយ ចូលចាប់ប្រវា ។
ឈរឈានបីបានបុត្រា ទាំងពីរអង្គា ចុះទូកវិលវៃ ។
បុត្រាសោភាពេកក្រៃ អារឡោះអាល័យ មាតាបិតា ។
ផ្កាខ្លោចលន្លោចឱព ខ្លាចព្រានព្រៃវា ប៉ុបាត់ជីវី ។
យំទួញទំនួញទៅខ្មី រកក្សត្រទាំងទ្វី ញ័ររអស់អង្គា ។
៨៥- ឯចៅប្អូនពៅពុំងា សោតសឹងសោកា ទួញទៅជននី ។
ក្បៀណនោះព្រានស្មោះចេញពី ឆ្មៀរឆ្មេរជលធី គ្រាច់ត្រង់ជលសា ។
អុំទៅលំនៅអាត្មា ដាស់តឿនដេរគ្នា ពុំឲ្យសម្រាន្ត ។
រុករះលាកលះទើបបាន ទៀងទៅត្រើះស្ពាន ទាល់តត្ថសិលា ។
ឯអង្គពីរពង្សក្សត្រា ព្រានពីរចែកគ្នា យកទៅទីទៃ ។
៩០ ព្យាបាលកុមារថ្លាថ្លៃ ថ្នាក់ថ្នមសព្វថ្ងៃ ពុំឲ្យមានហ្មង ។

## បទព្រហ្មគីតិ

៧០ នេះយើងនឹងស្រដី ដំណើរពីក្សត្រច្បាស់ច្បង
កាលស្ដេចហិចហែលឆ្លង នាំនាងនាថរាជធីតា ។
ព្រះអង្គឈប់សម្រាន្ត លង់លុះបានស្រោងសះយា
ព្រះអង្គតែងសោកា និត្យនៅលើគោកថ្នាក់ថ្នល់ ។



គន់គិតរាជបុត្រា នៅកំព្រាព្រាត់ទុព្វល
ព្រះអង្គសោកាណាស់ នូវនាងនាថរាជទេវី ។
ស្ដេចផ្ដាំវរជាយា រាជធីតាអគ្គមហេសី
ប្អូនអើយបងនឹងលី- លាទៅថ្កានបុត្រទ្វេហារ ។
ចូរចៅនៅប្រយ័ត្ន ក្រោយព្រៃងសត្វវាហ៊ឹង្សា
ប្អូនចាំនៅនេះណា នេត្រវំពៃសព្វទិសទី ។
៧៥ បងនឹងលាទៅផ្គង ទៅចម្លងបុត្រទាំងទ្វី
ឲ្យជួបជួនទាំងបី ស្រេចហើយបងនឹងរុនរាន ។
ចរចេញពីនេះទៅ កាត់សំដៅព្រៃហិមពាន្ត
នាងនៅឲ្យសុខសាន្ត សោះអំពល់សេចក្ដីគិត ។
សន្សំស្រាងសីលា ពឹងព្រឹក្សាឲ្យស្នេហ៍ស្និទ្ធ
ដរាបអស់ជីវិត ឲ្យរៀងរូចព្យេរវេលា ។
ស្ដេចផ្ដាំហើយផ្ដាំទៀត ទ្រុងចង្កៀតឈើខ្លោចផ្កា
ស្រយុតអស់អង្គា គិតព្រះប្អូនពន់ពេកសល់ ។
នាងនាថសឹងសោយសោក សែនអមោក្យផ្ដាំទសពល
ព្រះនេត្រាជោរជល ស្រក់សស្រោកព្រះភក្ត្រា ។
៨០ ព្រះអើយបើព្រះបង ទៅចម្លងបុត្រទ្វេហារ
ព្រះអង្គឆាប់រូសរាំ កុំស្ដេចចោលខ្ញុំលន្លង់ ។
ខ្ញុំខ្លាចព្រៃនេះស្ងាត់ ឮសព្វសត្វស្រៀវស្រែកក្នុង
ព្រឹក្សាបើរាយង់ យល់ចោមងាប់ជាចំណី ។

ស្តេចលោមស្តេចលាកលា    វរជាយាអគ្គបហេសី
ផ្តែផ្តាំស្រេចអស់ក្តី    ហើយស្តេចចុះក្នុងគង្គា ។
កាលនោះពោធិសត្វ    បុរសរ័ត្នស្តេចលីលា
ហែលឆ្លងក្នុងជលសា-    គរគម្ពីរជ្រាលជ្រៅ ។
ស្តេចហែលហើយសោយសោក    សែនអមោក្សឱពក្តៅ
គន់គិតត្បិតនាងនៅ    ក្រោយកំព្រាព្រាត់ឃ្លាឃ្លៃ ។
៨៥- ឱអាសូរប្អូនក្តាត់    ម្ល៉េះសមស្វាត់ឯក្រោយក្រៃ
និត្យនៅកណ្តាលព្រៃ    ព្រឹក្សស្មស្មានឯងឯកអង្គ ។
ម្ល៉េះហើយសមប្អូនស្ងួន    មាសខ្លឹមខ្លួននាងនាថទ្រង់
កន្សែងសោកឡឹនឡង់    តែងទន្ទឹងទល់ទុក្ខា ។
ឱបងអាសូរថៅ    ចាំនិត្យនៅក្នុងព្រឹក្សា
សមខ្លាចសត្វម្រឹគា    ញ៉រន្ធត់អស់ឥន្ទ្រិយ ។
តែងមើលផ្លូវបងចាត់    ហើយប្អូនរ័ត្នសោយសោកពី-
លាបលន់ជន្មជីវី    នៅកណ្តាលព្រៃអថ្វា ។
បងមហាថប់ពេកក្តាត់    មួយក្រែងសត្វភិពាធា
យកប្អូនទៅគោក្តា    អសារស្នេស្នសោះបង់ម្សៀត ។
៩០ ព្រះអង្គសោយសោកា    ឈឺខ្លោចផ្សាទ្រូងចង្អៀត
ស្តេចទ្លួញហើយទ្លួញទៀត    នៅកណ្តាលគម្ពីរា ។
ដំណើរពោធិសត្វ    បុរសរ័ត្នស្តេចលីលា
ហិចហែលក្នុងគង្គា    យើងបញ្ឈប់ស្ទេះសិនហោង ។



ទើបយើងនឹងសម្តែង    និទានថ្លែងដោយទំនង
កាលក្រោយក្សត្រច្បាស់ច្បង    ពានគេត្រាបើកចេញចរ ។
ឯនាយគេត្រានោះ    សោតនាមឈ្មោះហៅសាគរ
ពាណិជនាំអស់ប-    រិពារប្រាំរយគណនា ។
បើកក្តោងផ្តោះសំដៅ    តម្រង់ទៅនគរា
បើកតាមឆ្នេរជលសា    លុះព្រឹកព្រាងស្រេចមកដល់ ។
៩៥ ដែនដាក់នាងធីតា    វរជាយារ័ត្ននិម៌ល
នៅនាទីថ្នាក់ថ្នល់    ទៅទឹមទៀបវរជាយា ។
ខ្លះប្រាប់នាយសំពៅ    ជាអ្វីនំដូចមនុស្សា
គួរយើងបោះយុថ្កា    ចូលទៅមើលឲ្យប្រាកដ ។
ខ្លាចក្រែងអស់ទេព្តា    នៅរក្សាឆ្នេរសមុទ្រ
ឬមួយមនុស្សកំសត់    ក្រែងវង្វេងព្រៃព្រឹក្សា ។
ទើបអស់អ្នកទាំងនោះ    ដាក់ក្តោងស្មោះបោះយុថ្កា
ស្រេចហើយទើបនាយពា-    ណិជនាំគ្នាយចុះសំប៉ាន ។
ចែវចូលដោយជោរជល    លុះបានដល់ឆ្នេរត្រើយត្រាណ
ឯនាយឡើងទៅថ្កាន    យល់នាងនាថឆោមប្រពៃ ។
១០០ ក្ដួចកើតកាន់ស្នេហ៍ស្និទ្ធ    ត្រេកអរក្តាត់នឹងស្រីថ្លៃ
សាសងសួរសម័យ    សព្វដំណើរវរជាយា ។
នាងប្រាប់ដោយសេចក្តី    ជាស្វាមីខ្ញុំយាត្រា
ហិចហែលក្នុងគង្គា    ទៅយកបុត្រទាំងពីរពង្ស ។

នាងប្រាប់អស់ប្រការ　ឯភាពក្លួចចិត្តចង
ថាហៃប្អូនស្នេហ៍ស្នង　កុំទៅចាំនៅនេះណា ។
អញបងនឹងយកទៅ　រួមលំនៅជាភរិយា
កុំប្អូនដោះសាថា　ធ្វើកោតការក្ដីឆ្នាំឆ្នង ។
អញបងបានពើបពះ　ជួបប្រទះមាសស្នេហ៍ស្នង
អញនឹងរក្សាគ្រង　ជាភរិយារួមមេត្រី ។
១០៩ នាងស្ដាប់នាយគេត្រា　ភិតភក្ក្រាញ់ឥន្ទ្រិយ
សែនសោកព្រះស្វាមី　ដួលសន្លប់សុន្យសុបសៅ ។
វែងនាយគេត្រា　បីជាយាចុះសំពៅ
ប្ដីម្នាបើកសំដៅ　ទៅកណ្ដាលសាគរ ។
កាលនោះនាងទេវី　អគ្គមហេសីរាជធីតា
នាងភិតញ័រអង្គា　យល់អស់ពាណិជទាំងឡាយ ។
នាងវែងសោយសោកា　ទួញព្រះមហាក្សត្រពណ្ណរាយ
ផ្កាខ្លោចឈើសព្វសាយ　វែងតានតឹងឱរត្ត ។
ទួញថាឱព្រះបង　ប្អូនមករងទុក្ខពេកក្ដាត់
ជាឱព្រះមហាក្សត្រ　ស្ដេចវែងទ្រង់ព្រះមេត្តា ។
១១០ មិនដឹងជាប្អូនស្រី　កើតទុក្ខថ្មីដល់ម៉្លេះណា
មកនៅនឹងអស់ពា　ណិជគេត្រាយកប្អូនទៅ ។
ឱម៉្លេះសមព្រះបង　វិលមកហោងរកប្អូនពៅ
ពុំឃើញគេរកហៅ　សព្វកណ្ដាលព្រៃព្រឹក្សា ។



នូអាសូរបុត្រពៅ　ម៉្លេះយំរបោរកមាតា
សង្រេងឈើខ្លោចផ្កា　ក្បែយជីវិតសុន្យបោះបង់ ។
ម៉្លេះសមបុត្រជាច្បង　សមនឹងរងទុក្ខលុះលង់
ជន្មជីវិតពីរពង្ស　នៅឆ្ងៀរឆ្ងរត្រើយសាគរ ។
នាងទ្រង់កន្សែងសោក　សែនអមោឃនិរន្តរ
ព្រះហស្តទាំងពីរគរ　គក់ឱរជាំក្រំក្រៃ ។
១១៩ នាងអត់គោជនា　គំរប់ជាប្រាំពីរថ្ងៃ
តែងទួញទៅក្សត្រថ្លៃ　នូវបុត្រាទាំងពីរពង្ស ។
ឈើផ្សៀបផ្កាប្រមាត់　ដូចគេកាត់គេកួរក្នុង
ពុងពោះបោកបោះបង់　ជានិរន្តរទៀងទាត់ ។
នាយគេត្រាត្រេកត្រិះ　លោមសំណោះប្រតិព័ទ្ធ
នាងនាថពុំស្នេហ៍ស្និទ្ធ　ពុំមេត្រីត្រេកចិន្ដា ។
ហេតុតែគេផះផល　នាងនិម៌លបានប្រាថ្នា
អំពីមុនច្រើនគ្រា　នឹងព្រះពង្សពោធិសត្វ ។
ចំណោរនឹងបានត្រាស់　សម្ពុទ្ធច្បាស់ពុំឃ្លាឃ្លាត
ក្សត្រីជួបជាក់ជាតិ　ជាកន្សៃព្រះប្រាជ្ញា ។
១២០ នាយគេត្រចង់ប្រមាទ　នៃនាងនាថជាពនិតា
នឹងចូលផិតអង្គា　ហើយក្ដៅក្ដាត់ដូចអគ្គី ។
អស់ទាំងអ្នកគេត្រា　រួមរក្សានាងទេវី
សឹងគោរពព្រះបារមី　ពិតពុំហ៊ានក្លួចគាមា ។

នាងនាថនារីរ័ត្ន　　តែងគន់គិតមហាក្សត្រា
នូវបុត្រទាំងទ្វេហារ　　ជាទុក្ខទ្វេងឯងឯកនៅ ។
ចាថែងថ្លែងសម្ដី　　ដំណើរពីអ្នកសំពៅ
សង្កិតស្នេះទុកនៅ　　នឹងថ្វាថ្លែងឯពោធី ។

## បទពំនោល

កាលនោះព្រះមហាក្សត្រថៃ(១) ស្ដេចហែលជលធី កាត់ត្រង់តម្រង់ត្រើយត្រាណ។
លង់លុះដល់ចុងខ្សាច់បាន　ស្ដេចឡើងទៅថ្កាន　រូសរកបុត្រាពីរពង្ស ។
ពិតពុំយល់ឡើយព្រះអង្គ　រត់រកហៅក្នុង　ព្រះព្រៃពន្លឹករលេងល្វើយ ។
ឱអ្នកមាសអាពុកអើយ　អាពុកមកហើយ　រកបាបាត់ទៅឯណា ។
ឬមួយសត្វផងពាធា　យកទៅភោក្តា　បុត្ររ័ត្នទាំងពីរបង់បាត់ ។
កាលនោះព្រះពោធិសត្វ　សោករាជបុត្ររ័ត្ន　ស្ដេចដួលសន្លប់លុះលង់ ។
ភ្ញាក់ស្មារតីព្រះអង្គ　ស្ដេចទ្វេងទួញទ្រង់　កន្សែងស្ដេចសោយសោកា។
ឱបាបុត្រពីរអង្គា　បានៅស្ថានណា　អាពុករកហៅល្វេងល្វើយ ។
ម្ដេចពុំឮមាត់បាឆ្លើយ　ឬបាក្ស័យហើយ　សត្វផងពិឃាដភោក្តា ។
ឬមួយក្រែងអស់ទេព្តា　យកបុត្រពុំងា　ទៅលាក់នៅស្ថានព្រឹក្សព្រៃ។
ស្ដេចសោយសោកាណាស់ក្រៃ　ស្រក់ទឹកនេត្រនៃ　សស្រាក់សស្រោកកក្រា ។
ប្រែប្រាណនៀលអង្គា　ក្ដៅក្ដាត់ឱរា　ផ្ទុកផ្ទើះទង្គិះខ្សឹកខ្សួល ។
ទ្រងត្រូវសាច់ស្វិតរំដួល　ផ្ទុកផ្ទើះទង្គួល　បារម្ភព្រះរាជបុត្រា ។
ស្ដេចរកដោយផងបព្វតា　សព្វស្ថានព្រឹក្សា　សព្វច្រកជ្រលងជ្រងជ្រោះ ។
ពុំយល់បុត្ររ័ត្នសូន្យសោះ　រកសព្វចន្លោះ　ដោយដងតុម្ពោតព្រឹក្សព្រៃ ។

---
១ ច្បាប់ ១ ថា　កាលនោះព្រះជីភូមិ ។



ពុំយល់ឡើយលុះក្សត្រថៃ　សែនសោកាក្រៃ　រន្ធត់អស់អង្គឥន្ទ្រិយ ។
ទើបស្ដេចវិលវែងទៅខ្ទី　ស្ថានដែលពោធិ　ទុកព្រះរាជបុត្រនោះណា ។
ក្រោះដើមទម្លាប់ព្រឹក្សា　ផ្ដេករាជបុត្រា　មើលមានស្នាមជើងជាក់ជាន់ ។
ស្ដេចទ្រង់ចិន្ដាគ្នេរគ្នាន់　ទើបក្សត្រសោភ័ណ　ឈ្វេងយល់ដោយព្រះប្រាជ្ញា ។
ដឹងដើមមានមនុស្សយាត្រា　ត្រាច់ព្រៃព្រឹក្សា　មកឃើញបុត្រាពីរពង្ស ។
រើសយកនាំទៅពុំលង់　ឡើយលុះព្រះអង្គ　ជ្រាបជាក់អស់អាថ៌សេចក្ដី ។
កាលនោះព្រះពង្សពោធិ　វែងសោយសោកពី　លាបលន់ពន្លឹកថ្លែងថា ។
ឱបាបុត្រពីរអង្គា　វែងពេញចិន្ដា　អាពុកពុំដែលឲ្យហ្មង ។
អាពុកទុកបុត្រច្បាស់ច្បង　ឲ្យនៅគ្រប់គ្រង　រក្សាអនុជស្និទ្ធស្នេហ៍ ។
ឱម្ល៉េះហើយសមបាតែ　សោយសោកឥតល្ហែ　រស់រកពុំយល់ជននី ។
ឱសមលុះនៅជិរី　ញៀតក្មេងសេចក្ដី　ពិតពុំបានបៅមាតា ។
អាពុកពុំឃើញបុត្រា　ទាំងពីរអង្គា　ស្មើថើមដង្ហើមហឫទ័យ ។
ទ្រង់សោយសោកពន់ពេកក្រៃ ហៀបហាក់នឹងក្ស័យ　ជីវិតនៅឆ្នេរគង្គា ។
ហើយស្ដេចគិតនឹងលីលា　ទៅប្រាប់ធីតា　ឲ្យនាងដឹងដើមបុត្របាត់ ។
កាលនោះព្រះពោធិសត្វ　ស្ដេចហែលវែងថ្វាត់　កណ្ដាលសាគរគម្ពីរ ។
ស្ដេចអត់អាហារចំណី　ជាថ្ងៃប្រាំពីរ　សន្ធែសន្ធឹកខ្លោចផ្សា ។
នឿយណាស់ស្ទើរក្ស័យជន្មា　កណ្ដាលជលសា　ជ្រាលជ្រៅពន្លឹកគួរស្ញែង ។
រលកបោកបែកផ្កាត្រែង　រំជំរំជែង　អ័ព្ទអស់ងងឹតទិសា ។
មើលនាគនូវមករហែលហា　ចឹកចាប់មច្ឆា　គគ្រេងកក្រើកជលធី ។
ឆ្លាមឆ្លាំងលេបមច្ឆាស៊ី　ដង្កៀតកៀងកាលញី　ក្រពើកៀងកាយមច្ឆា ។
ត្រីឆ្តោរាហូត្រីប្រា　ត្រីឆ្តង់ត្រីខា　ផ្អើលរត់រជោតិតភ័យ ។